**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តឧត្តរមានជ័យ**
លេខ: ០៧៦ សជណ.ខ្ជ

ឧត្តរមានជ័យ,ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលចំពោះការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣

**យោង** ៖ លិខិតលេខ ១៧២០ អពដ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ ស្តីពីការពន្យារពេលចំពោះការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ** សូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់មេត្តាជ្រាបថា ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ ត្រូវបានពន្យារពេលចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី **៣១ ខែ តុលា ឆ្នាំ ២០១៣** បន្តទៀត នៅសាខាពន្ធដារខេត្តឧត្តរមានជ័យ ។ ឯការផាកពិន័យលើការបង់ពន្ធនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី **០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣** តទៅ ។

ក្នុងអំឡុងពេលពន្យារការប្រមូលពន្ធនេះ សាខាពន្ធដារខេត្តឧត្តរមានជ័យ ត្រូវពិនិត្យ និង ប្រើប្រាស់កម្លាំងមន្ត្រីឱ្យអស់លទ្ធភាព និង បន្ថែមថ្ងៃធ្វើការសៅរ៍-អាទិត្យ ព្រមទាំងជំរុញការផ្សព្វផ្សាយនៅតាមភូមិ-សង្កាត់នីមួយៗ ដើម្បីចលនាម្ចាស់អចលនទ្រព្យ(គឺអ្នកមានដី ផ្ទះ អគារ និង សំណង់ផ្សេងៗ ) ដែលនៅសេសសល់ បានមកប្រកាសបង់ពន្ធទាន់ពេលវេលា ដែលនឹងត្រូវបញ្ចប់នៅថ្ងៃទី **៣១ ខែ តុលា ឆ្នាំ ២០១៣** ខាងមុខនេះ ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ពិតជាមានការភ្ញាក់រលឹកខ្ពស់ ហើយសូមអញ្ជើញមកបំពេញកាតព្វកិច្ចបង់ពន្ធនេះ អោយបានរួសរាន់ទាន់ពេលវេលាកំណត់ជាពុំខានឡើយ ។

**អភិបាលខេត្ត**

ស_ថាវី

**ចម្លងជូន** ៖
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត

( ដើម្បីជូនជ្រាប )

- សាខាពន្ធដារខេត្ត
- សាលាក្រុងសំរោង
- សង្កាត់ទាំង ៥

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ